ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
FAX / PHONE : (855) 23 427 798

លេខ: ០១៩.......សជណ.សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០

# សេចក្តីជូនដំណឹង

ស្តីពី

## វិធានការចំពោះការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបជូនដំណឹងដល់ឯកឧត្តម-អ្នកឧកញ៉ា លោក-លោកស្រី ដែលមានដីត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មេត្តាជ្រាបថា : ចាប់តាំងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្សព្វផ្សាយជាសាធារណៈតាមវិទ្យុ-ទូរទស្សន៍ និងសារពត៌មាននូវសេចក្តីជូនដំណឹងលេខ ០១០ សជណ.សហវ.ពដ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីវិធានការចំពោះការគ្រប់គ្រងនិងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងបន្ទាប់ពីសាលាខេត្ត-ក្រុងនីមួយៗបានធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះ តាមវិទ្យុ-ទូរទស្សន៍ និងសារពត៌មានមក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសង្កេតឃើញថា ឯកឧត្តម-អ្នកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់កម្មសិទ្ធិនៃដីធ្លីមិនបានប្រើប្រាស់ បានអញ្ជើញមកប្រកាសបង់ពន្ធជាបន្តបន្ទាប់ រហូតមកដល់ពេលនេះសំរេចបាន ៧០% នៃផែនការ ។

លទ្ធផលដែលសំរេចបានខាងលើនេះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពីសំណាក់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាលខេត្ត-ក្រុង ប្រធាន អនុប្រធាន គណៈកម្មការ អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ខេត្ត-ក្រុងដែលបានជួយជំរុញដោយផ្ទាល់ក្នុងការប្រមូលចំណូលនេះ និងដោយមានការភ្ញាក់រលឹកខ្ពស់គោរពច្បាប់ សស្រាក់សស្រាំអញ្ជើញមកបង់ពន្ធពីសំណាក់ម្ចាស់កម្មសិទ្ធិនៃដីធ្លីមិនបានប្រើប្រាស់ម្នាក់ៗ ។

ទន្ទឹមនឹងនេះ ក៏នៅមានម្ចាស់កម្មសិទ្ធិនៃដីធ្លីមិនបានប្រើប្រាស់មួយចំនួនរឹងរូសមិនព្រមអញ្ជើញមកប្រកាសបង់ពន្ធតាមពេល និងទីកន្លែងកំណត់ តាមសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាសាលាខេត្ត-ក្រុង ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមប្រកាសជូនដំណឹងជាថ្មីម្តងទៀត ដើម្បីរំលឹកដល់ឯកឧត្តម-អ្នកឧកញ៉ា លោក-លោកស្រី ដែលមានដីត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ សូមមេត្តាប្រញាប់ប្រូសរាន់អញ្ជើញមកប្រកាសបង់ពន្ធឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០០ ។ ករណីម្ចាស់កម្មសិទ្ធិនៃដីធ្លីមិនបានប្រើប្រាស់មិនព្រមមកទំនាក់ទំនងប្រកាសបង់ពន្ធ ដូចបានកំណត់ខាងលើនេះទេ រាជរដ្ឋាភិបាលនឹងចាត់ទុកថាដីគ្មានម្ចាស់ ហើយនឹងមានវិធានការប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ព្រមទាំងអនុវត្តនូវវិធានការតឹងទារនានាទៅតាមការកំណត់នៃច្បាប់ស្តីពីសារពើពន្ធ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសង្ឃឹមនិងជឿជាក់ថា ឯកឧត្តម-អ្នកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់កម្មសិទ្ធិលើដីធ្លីមិនបានប្រើប្រាស់ទាំងអស់ប្រាកដជាបានយល់ដឹងនឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋបានល្អជាពុំខាន ។

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- សាលាខេត្ត-ក្រុង "ដើម្បីជួយជំរុញនិងផ្សព្វផ្សាយ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ.កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់